ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តព្រះសីហនុ**

សំណុំរឿងព្រហ្មទណ្ឌលេខ៦១១ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២០
សំណុំរឿងជំនុំជម្រះលេខ៧៦៦ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០
កាលបរិច្ឆេទសវនាការថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០
កាលបរិច្ឆេទប្រកាសសាលក្រមថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០
សាលក្រមលេខ: ..១០១១..../..១០៦...... (ឈ)
ចុះថ្ងៃអង្គារ ១១កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស២៥៦៤
ត្រូវនឹងថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាដំបូងខេត្តព្រះសីហនុ

**បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តព្រះសីហនុ**

**ដោយមានសមាសភាពដូចតទៅ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តព្រះសីហនុ

**ចៅក្រមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តព្រះសីហនុ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តព្រះសីហនុ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តព្រះសីហនុ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តព្រះសីហនុ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ៦១១ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ លើជនជាប់ចោទដូចខាងក្រោម៖

ឈ្មោះ [redacted] **វ៉ន** ភេទប្រុស អាយុ ៥២ឆ្នាំ ជនជាតិខ្មែរ មុខរបរ កម្មករសំណង់ កម្រិតវប្បធម៌ មិនបានរៀន មានទីកន្លែងកំណើតនៅភូមិក្រាំងលាយ ឃុំអង្គរមាស ស្រុកឈូក ខេត្តកំពត មានទីលំនៅមុនពេលឃុំខ្លួននៅភូមិ [redacted] ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០៥នាក់ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ប្រវត្តិនៃផ្តន្ទាទោសពីមុនដោយតុលាការ "គ្មាន" ។ **(ក្នុងឃុំ)**

ជាប់ចោទពីបទ ៖ **រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ** ប្រព្រឹត្តនៅភូមិចំណោទរាម ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីអំឡុងខែកញ្ញា ឆ្នាំ២០១៩ ដល់អំឡុងខែមីនា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

ដោយមានលោក [redacted] **លីដា** ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

ជនរងគ្រោះឈ្មោះ [redacted] **ចន្ធី** ភេទស្រី អាយុ ១៣ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិ[illegible] ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៥០៨៩ អ.យ.ខ/២០ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ ។



Scanned with CamScanner

បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៣៦១៥ ត.ព/២០ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ។

បានឃើញ ដីកាសម្រេចកំណត់កាលបរិច្ឆេទជំនុំជម្រះលេខ ៣៩៣៣ ត.ព.វ/២០ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០ របស់ប្រធានសាលាដំបូងខេត្តព្រះសីហនុ។

## អង្គហេតុដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យមានដូចតទៅ

កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង ០៩ព្រឹក ស្ថិតនៅភូមិចំណោទរាម ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ជនសង្ស័យឈ្មោះ [redacted] **វិន** បានរួមភេទជាមួយជនរងគ្រោះឈ្មោះ [redacted] **ចន្នី** ភេទស្រី អាយុ ១២ឆ្នាំ ដែលបានស្នាក់នៅជាមួយ។ ក្រោយមកជនរងគ្រោះបានប្រាប់រឿងរ៉ាវទៅកាន់ជីដូនឈ្មោះ [redacted] **សុភាព** ដោយប្រាប់ទៀតថា ជនសង្ស័យបានសន្យាជាមួយខ្លួនថា នឹងទិញម៉ូតូមកឱ្យ។ បន្ទាប់ពីឮដំណឹងនេះ ឈ្មោះ [redacted] **សុភាព** បានសួរនាំឈ្មោះ [redacted] **វិន** អំពីរឿងរ៉ាវទាំងនោះបណ្តាលឱ្យឈ្លោះប្រកែកគ្នា និងបណ្តេញឈ្មោះ [redacted] **វិន** ចេញពីផ្ទះ។ រហូតដល់អំឡុងខែមីនា ឆ្នាំ២០២០ ជនរងគ្រោះឈ្មោះ [redacted] **ចន្នី** បានប្រាប់ឈ្មោះ [redacted] **សុភាព** ថា ឈ្មោះ [redacted] **វិន** បានមកសុំខ្លួនរួមភេទទៀត និងបានទិញទូរស័ព្ទដៃ ០១គ្រឿង ឱ្យទៅជនរងគ្រោះ ក្រោយពីសួរនាំជនរងគ្រោះទើបដឹងថាឈ្មោះ [redacted] **វិន** ធ្លាប់បានលួងលោមរួមភេទជាមួយជនរងគ្រោះជាច្រើនដងបានសម្រេច។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **វិន** បានឆ្លើយថា ៖ ជនរងគ្រោះឈ្មោះ [redacted] **ចន្នី** ជាចៅរបស់ប្រពន្ធខ្លួនឈ្មោះ [redacted] **សុភាព**។ កាលពីអំឡុងឆ្នាំ២០១៩ រហូតដល់ខែមីនា ឆ្នាំ២០២០ ខ្លួនបានរួមភេទជាមួយជនរងគ្រោះជាច្រើនដង ដោយខ្លួនមិនបានដឹងថាចំនួន ប៉ុន្មានដងនោះទេ ដោយខ្លួនគ្រាន់តែដឹងថាច្រើនដង។ ខ្លួនមិនបានដឹងថាឈ្មោះ [redacted] **ចន្នី** មានអាយុប៉ុន្មានឡើយ ហើយនៅពេលរួមភេទមិនបានបង្ខំជនរងគ្រោះឡើយ។ ចំពោះរឿងរួមភេទជាមួយគ្នានេះ ជនរងគ្រោះជាអ្នកចាប់ផ្តើមមុន ដោយដំបូងគេបាននិយាយលេងជាមួយខ្លួន និងបន្ទាប់មកគេបានដេកពីលើខ្លួន។ ខ្លួនបានរួមភេទជាមួយជនរងគ្រោះរយៈពេល ០១ឆ្នាំមកហើយ ដោយខ្លួនបានរួមភេទជាមួយជនរងគ្រោះ ០១សប្តាហ៍ ០១ដង ទៅ ០២ដង។ នៅថ្ងៃកើតហេតុខ្លួនបានហៅជនរងគ្រោះមកធ្វើសាច់មាន់ហូប ហើយត្រូវបានប្រពន្ធដឹង ទើបគាត់ប្តឹងខ្លួនតែម្តង។ នៅពេលខ្លួនបានរួមភេទជាមួយចៅនោះ ពេលខ្លះប្រើស្រោម និងពេលខ្លះទៀតមិនបានប្រើស្រោមអនាម័យឡើយ។ ខ្លួនមិនបានលួងលោមជនរងគ្រោះដើម្បីរួមភេទនោះទេ ហើយខ្លួនធ្លាប់បានទិញក្រវិលឱ្យជនរងគ្រោះម្តងដែរ។

-សាក្សីឈ្មោះ [redacted] **សុភាព** បានឆ្លើយថា ៖ ខ្លួនជាប្រពន្ធរបស់ឈ្មោះ [redacted] **វិន** ហើយគេជាប្តីក្រោយរបស់ខ្លួន ចំណែកជនរងគ្រោះឈ្មោះ [redacted] **ចន្នី** ជាចៅរបស់ខ្ញុំ ដោយឪពុកគេបានជាប់ពន្ធនាគារ ចំណែកម្តាយរបស់គេបានស្លាប់ហើយ។ ខ្លួនមិនដែលបានឃើញប្តីរបស់ខ្លួន ចាប់រំលោភលើជនរងគ្រោះនោះទេ ហើយខ្លួនបានដឹងរឿងហេតុនេះតាមរយៈឈ្មោះ **ចន្នី** បានប្រាប់ខ្លួនថា "**តាបបួលខ្លួនចុយគ្នារាល់ថ្ងៃ សន្យាទិញម៉ូតូឱ្យខ្ញុំ គ្មានឃើញមានម៉ូតូស្អីនោះទេ**" ក្រោយពេលឮដូច្នេះ នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩ ពេលព្រឹក ខ្លួនបានវាយតានោះ ហើយនាពេលនោះខ្លួនបានលើកលែងឱ្យជនជាប់ចោទ ក្រោយមកទើបខ្លួនបានដាច់ចិត្តដាក់ពាក្យបណ្តឹងតែម្តង។ នៅពេលនោះជនរងគ្រោះបានប្រាប់ថា ប្រើស្រោមអ[redacted] វារាល់ថ្ងៃ ហើយខ្លួនបានទុកពេលឱ្យគាត់រយៈពេល ០១ឆ្នាំ តែគាត់នៅតែមិនកែប្រែ ទើបខ្លួនប្តឹងគាត់តែម្តង។ ខ្លួនបានយកតានោះ ចាប់តាំងពីឆ្នាំ១៩៨៤មក ចំណែកចៅដែលជាជនរងគ្រោះបានមករស់នៅជាមួយខ្លួនតាំងពីអាយុ ០៩ឆ្នាំមកម្លេះ ហើយចៅបានមករួមរស់ជាមួយខ្លួនរយៈពេល ០៤ឆ្នាំ ទើបមានរឿងកើតឡើង។ តានឹងគាត់បានដឹងអាយុចៅ ប៉ុន្តែគាត់ធ្វើមិនដឹង។ ចៅខ្ញុំបច្ចុប្បន្នអាយុ ១៤ឆ្នាំ ហើយនៅពេលកើតហេតុគេមានអាយុ ១៣ឆ្នាំ។ ខ្ញុំធ្លាប់បានដឹងថា ជនជាប់ចោទធ្លាប់បានរំលោភកូនស្រីខ្លួន (កូនប្តីដើម) ម្តងរួចមកហើយ។

-អំណានចម្លើយជនរងគ្រោះឈ្មោះ [redacted] ចន្នី បានឆ្លើយថា ៖ កាលពីអំឡុងខែកញ្ញា ឆ្នាំ២០១៩ ខ្លួនជួយលាបថ្នាំផ្ទះ ជាមួយជីតា ខណៈនោះជីតារបស់ខ្លួនឈ្មោះ [redacted] រិន បានសុំខ្លួនរួមរ័ក្ស ដោយគាត់បានសុំដដែលៗច្រើនដងពេក ខ្លួនបានយល់ព្រមរួមរ័ក្សជាមួយគាត់ម្តងនៅក្នុងផ្ទះ ក្រោយពេលរួមរ័ក្សរួចគាត់បានប្រាប់ខ្លួនថា មិនឱ្យខ្លួនប្រាប់យាយឡើយ បើខ្លួនហ៊ានប្រាប់គាត់នឹងវាយខ្លួន។ បន្ទាប់ពីបានរួមរ័ក្សជាមួយខ្លួនម្តងមកស្អែកឡើងគាត់បានសុំខ្លួនរួមរ័ក្សម្តងទៀត តែខ្លួនមិនព្រមគាត់ក៏បានចាប់ទាញដៃខ្លួនរួមរ័ក្សម្តងទៀត ហើយក្រោយពេលរួមរ័ក្សហើយ ខ្លួនមានអាការៈឈឺចុកចាប់យ៉ាងខ្លាំង និងមានឈាមហូរចេញពីប្រដាប់ភេទរបស់ខ្លួនទៀតផង។ ជារៀងរាល់ថ្ងៃនៅពេលយាយមិននៅ ជីតាតែងតែសុំខ្លួនរួមរ័ក្សជារៀងរាល់ថ្ងៃ ពេលខ្លួនមិនព្រមពេលខ្លះគាត់បានចាប់បង្ខំខ្លួន។ រយៈពេលប្រហែល ០៣ខែមកហើយ ដែលជីតាបានរួមរ័ក្សជាមួយខ្លួនរាល់ថ្ងៃ នៅពេលដែលខ្លួនឈឺចាប់ទ្រាំមិនបានក៏បានប្រាប់យាយថា ជីតាបានរួមរ័ក្សជាមួយខ្លួនសន្យាថានឹងទិញម៉ូតូឱ្យខ្លួន នៅពេលយាយគាត់បានដឹងរឿងហើយ ក៏បានឈ្លោះប្រកែកគ្នាជាមួយតា ហើយបានប្រាប់ខ្លួនថាឱ្យឈប់រួមរ័ក្សជាមួយតាទៀត។ បន្ទាប់មកបានរយៈពេលប្រហែល ០២ខែ យាយបានទៅលេងផ្ទះកូនប្រសារគាត់នៅខេត្តកំពត ហើយខ្លួនបាននៅផ្ទះជាមួយជីតា នៅពេលនោះជីតាបានសុំខ្លួនរួមរ័ក្សទៀត ខ្លួនក៏យល់ព្រម ពេលយាយមកពីខេត្តកំពតវិញ ខ្លួនបានប្រាប់គាត់ ចាប់តាំងពីពេលនោះមកជីតាបានរួមរ័ក្សជាមួយខ្លួនយូរៗម្តង ក្រោយមកប្រហែល ០១ខែ ជីតាបានទិញទូរស័ព្ទមកឱ្យខ្លួន។ ក្រោយមកខ្លួនបានទៅចំការជាមួយយាយ ហើយយាយបានសួរខ្លួនថា ជីតាមានបានសុំខ្លួនរួមរ័ក្សទៀត ឬអត់ ខ្លួនក៏បានប្រាប់គាត់ ទើបគាត់បាននាំខ្លួនទៅប៉ុស្តិ៍ប៉ូលិសដាក់ពាក្យបណ្តឹងតែម្តង។

-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ៖ ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ សាក្សី និងអំណានចម្លើយជនរងគ្រោះឃើញថា កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង ០៩ព្រឹក ស្ថិតនៅភូមិចំណោទរាម ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ពិតជាមានករណី **រួមភេទជាមួយអនីតិជន** បង្កឡើងដោយជនសង្ស័យឈ្មោះ [redacted] រិន ដែលបានធ្វើសកម្មភាពរួមភេទជាមួយជនរងគ្រោះឈ្មោះ [redacted] ចន្នី ភេទស្រី អាយុ ១២ឆ្នាំ នៅពេលដែលយាយមិននៅ ហើយជនរងគ្រោះបានប្រាប់យាយ ទើបយាយដាក់ពាក្យបណ្តឹង។ ចំពោះសកម្មភាពរបស់ជនជាប់ចោទបានធ្វើសកម្មភាពបែបនេះជាញឹកញាប់ ចំពោះចម្លើយជននេះបានឆ្លើយថា មិនបានដឹងថា ចៅដែលជាជនរងគ្រោះមានអាយុប៉ុន្មាននោះ គ្រាន់តែជាចម្លើយដែលឆ្លើយដោះសារ និងគេចវេសពីការទទួលខុសត្រូវ និងមិនទទួលស្គាល់កំហុស។ ហេតុនេះតំណាងអយ្យការរក្សាបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] រិន តាមដីកាសន្និដ្ឋានស្ថាពរលេខ ៥០៨៩ អ.យ.ខ/២០ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ ទុកជាបានការដដែល និងស្នើសុំដល់ក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តន្ទាទោសលើជនជាប់ចោទរូបនេះជាអតិបរមានៃទោសជាប់ពន្ធនាគារ។

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ៖ ក្រោយពេលសាកសួរដេញដោលនាពេលសវនាការ និងពិនិត្យភស្តុតាងនានាដែលមានក្នុងសំណុំរឿងរួចមក ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទយល់ឃើញថា កូនក្តីខ្លួនបានឆ្លើយសារភាព និងដឹងកំហុសរបស់ខ្លួន។ ហេតុនេះស្នើសុំដល់ក្រុមប្រឹក្សាជំនុំជម្រះមេត្តាផ្តល់ស្ថានសម្រាលដល់កូនក្តីខ្លួនផង។

-សំណូមពររបស់ជនជាប់ចោទឈ្មោះ [redacted] រិន ៖ ខ្លួនស្នើសុំដល់តុលាការជួយរកយុត្តិធម៌ដល់ខ្លួនផង។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់ចម្លើយសាក្សី

ក្រោយពីបានស្តាប់អំណានចម្លើយជនរងគ្រោះ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានកត់សំគាល់របស់តំណាងអយ្យការប្តឹងសុំ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ


Scanned with CamScanner

## សាលាដំបូងខេត្តព្រះសីហនុ

## យល់ឃើញថា

**១.**ជនជាប់ចោទឈ្មោះ [redacted] **វិន** បានឆ្លើយថា ៖ កាលពីអំឡុងឆ្នាំ២០១៩ រហូតដល់ខែមីនា ឆ្នាំ២០២០ ខ្លួនពិតជាបានរួមភេទជាមួយជនរងគ្រោះជាច្រើនដង ក្នុង ០១សប្តាហ៍ ០១ដង ទៅ ០២ដង ដោយខ្លួនមិនបានដឹងថាសរុបចំនួនប៉ុន្មានដងឡើយ ដោយខ្លួនគ្រាន់តែដឹងថាច្រើនដង។ ខ្លួនបានរួមភេទជាមួយជនរងគ្រោះរយៈពេល ០១ឆ្នាំមកហើយ ដោយនៅថ្ងៃកើតហេតុខ្លួនបានហៅជនរងគ្រោះមកធ្វើសាច់មាន់ហូប ហើយត្រូវបានប្រពន្ធដឹង ទើបគាត់ប្តឹងខ្លួនតែម្តង។ នៅពេលខ្លួនបានរួមភេទជាមួយចៅនោះ ពេលខ្លះប្រើស្រោម និងពេលខ្លះទៀតមិនបានប្រើស្រោមអនាម័យឡើយ។ ដែលចម្លើយរបស់ជនជាប់ចោទខាងលើ មានភាពស៊ីសង្វាក់ទៅនឹងចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] **ចន្ទី** ដែលបានឆ្លើយថា កាលពីអំឡុងខែកញ្ញា ឆ្នាំ២០១៩ ខ្លួនជួយលាបថ្នាំផ្ទះឈ្មោះ [redacted] **វិន** ហើយគាត់បានសុំខ្លួនរួមរ័ក្ស ដដែលៗច្រើនដងពេក ខ្លួនបានយល់ព្រមរួមរ័ក្សជាមួយគាត់ម្តងនៅក្នុងផ្ទះ ក្រោយពេលរួមរ័ក្សរួចគាត់បានប្រាប់ខ្លួនថា មិនឱ្យខ្លួនប្រាប់យាយឡើយ។ លុះស្អែកឡើងគាត់បានសុំខ្លួនរួមរ័ក្សម្តងទៀត ហើយខ្លួនរួមរ័ក្សម្តងទៀត ហើយក្រោយពេលរួមរ័ក្សហើយ ខ្លួនមានអាការៈឈឺចុកចាប់យ៉ាងខ្លាំង។ រយៈពេលប្រហែល ០៣ខែមកហើយ ដែលជីតាបានរួមរ័ក្សជាមួយខ្លួនរាល់ថ្ងៃ នៅពេលដែលខ្លួនឈឺចាប់ទ្រាំមិនបានក៏បានប្រាប់យាយ។

**២.**តាមចម្លើយសាក្សីឈ្មោះ [redacted] **សុភាព** បានឆ្លើយថា ៖ ខ្លួនជាប្រពន្ធរបស់ឈ្មោះ [redacted] **វិន** ហើយគេជាប្តីរបស់ខ្លួន ចំណែកជនរងគ្រោះឈ្មោះ [redacted] **ចន្ទី** ជាចៅរបស់ខ្ញុំ។ ខ្លួនមិនដែលបានឃើញប្តីរបស់ខ្លួន ចាប់រំលោភលើជនរងគ្រោះនោះទេ ហើយខ្លួនបានដឹងរឿងហេតុនេះតាមរយៈឈ្មោះ **ចន្ទី** បានប្រាប់ខ្លួនថា **"តាបបួលខ្លួ**[redacted]**រាល់ថ្ងៃ សន្យាទិញម៉ូតូឱ្យខ្ញុំ គ្មានឃើញមានម៉ូតូស្អីនោះទេ"** ក្រោយពេលឮដូច្នេះ នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩ ពេលព្រឹក ខ្លួនបានវាយតានោះ ហើយនាពេលនោះខ្លួនបានលើកលែងឱ្យជនជាប់ចោទ ក្រោយមកទើបខ្លួនបានដាច់ចិត្តដាក់ពាក្យបណ្តឹងតែម្តង។ ចៅខ្ញុំឈ្មោះ [redacted] **ចន្ទី** ជាជនរងគ្រោះបច្ចុប្បន្នអាយុ ១៤ឆ្នាំ ហើយនៅពេលកើតហេតុគេមានអាយុ ១៣ឆ្នាំ។ ដែលចម្លើយរបស់សាក្សីខាងលើមានភាពស៊ីសង្វាក់ទៅនឹងសំបុត្របញ្ជាក់កំណើតលេខ៣៣ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៥ របស់មន្ត្រីអត្រានុកូលដ្ឋានឃុំបិតត្រាំង ឃើញថា ជនរងគ្រោះឈ្មោះ **ហាន ចន្ទី** កើតថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៧ ដែលមានអាយុ ១២ឆ្នាំ គិតត្រឹមថ្ងៃកើតហេតុពីអំឡុងខែកញ្ញា ឆ្នាំ២០១៩ ដល់អំឡុងខែមីនា ឆ្នាំ២០២០។

**៣.**តាមរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ចម្លើយរបស់ជនជាប់ចោទ ជនរងគ្រោះ សាក្សី និងភស្តុតាងអាចបញ្ជាក់បានថា ជនត្រូវចោទឈ្មោះ [redacted] **វិន** ពិតជាបានធ្វើសកម្មភាព រួមភេទជាមួយជនរងគ្រោះឈ្មោះ [redacted] **ចន្ទី** ភេទស្រី អាយុ ១២ឆ្នាំ ជាច្រើនលើកច្រើនសារ ដោយសន្យាទិញម៉ូតូ និងទូរស័ព្ទឱ្យជនរងគ្រោះ។ ដែលអំពើរបស់ជនជាប់ចោទខាងលើ ត្រូវបានច្បាប់កំណត់ថាជា **អំពើរួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ** បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រាមាត្រា៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

**៤.**អំពើរបស់ជនជាប់ចោទឈ្មោ [redacted] **វិន** បានធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម និងរូបរាងកាយរបស់បុគ្គល ហើយជនជាប់ចោទមានស្មារតីយល់ដឹងគ្រប់គ្រាន់ចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត និងក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន គប្បីតុលាការពិចារណាពីការផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌ។

**៥.**មានភស្តុតាង និងធាតុផ្សំគ្រប់គ្រាន់លើឈ្មោះ [redacted] **វិន** ភេទប្រុស ជនជាតិខ្មែរ ពីបទ ៖ **រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ** ប្រព្រឹត្តនៅភូមិចំណោទរាម ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីអំឡុងខែកញ្ញា ឆ្នាំ២០១៩ ដល់អំឡុងខែមីនា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

Scanned with CamScanner

<u>ហេតុដូច្នេះសម្រេច</u>

-ផ្តន្ទាទោសឈ្មោះ [redacted] ភេទប្រុស អាយុ ៥២ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) **ដាក់ពន្ធនាគារកំណត់ ០៥ (ប្រាំ)ឆ្នាំ** ពីបទ ៖ **រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ** ប្រព្រឹត្តនៅភូមិចំណោទរាម ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីអំឡុងខែកញ្ញា ឆ្នាំ២០១៩ ដល់អំឡុងខែមីនា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃច័ន្ទ ៣រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស២៥៦៤ ត្រូវនឹងថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃអង្គារ ១១កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស២៥៦៤ ត្រូវនឹងថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted]។

ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍នៅក្នុងកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] |

Scanned with CamScanner